**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានថ្លែងក្នុងឱកាសជួបសំណេះសំណាលជាមួយសហគមន៍ និស្សិត និងកម្មសិក្សាការីខ្មែរនៅប្រទេសជប៉ុន កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៨ **អំពីការមិនដោះដូរអធិបតេយ្យជាតិជាមួយបរទេស ការមិនយកសន្តិភាពរបស់ប្រទេសទៅដោះដូរជាមួយជំនួយ** ហើយប្រមុខរាជរដ្ឋាភិបាលបានបញ្ជាក់ជំហរយ៉ាងច្បាស់ថា **កម្ពុជាត្រូវប្រឹងរស់ងើបឈរឡើងដើម្បីការពារឯករាជ្យ អធិបតេយ្យ និងសន្តិភាពរបស់ប្រទេស។**

ជំហរដ៏មុឹងម៉ាត់របស់ **សម្តេចតេជោប្រមុខរាជរដ្ឋាភិបាល** នេះ ជាវីរៈភាពស្នេហាជាតិ មាតុភូមិ និងគោរពយ៉ាងខ្ជាប់ខ្ជួននូវរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងមាត្រា៥២ ដែលចែងថា "រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សាការពារទំនៀមទំលាប់ និងប្រពៃណីល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ"។

យើងខ្ញុំសូមប្រកាសគាំទ្រយ៉ាងឱឡារឹកបំផុត និងប្តេជ្ញាអនុវត្តយ៉ាងពេញទំហឹងនូវប្រសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខាងលើនេះ ដែលបង្ហាញឱ្យឃើញពីចរិត និងស្មារតីជាគោលការណ៍រឹងដូចដែកថែបដោយ "មិនយកអធិបតេយ្យឯកភាពជាតិ និងសន្តិភាពដូរជាមួយជំនួយ" និង "កម្ពុជាត្រូវមានសិទ្ធិអនុវត្តអធិបតេយ្យភាពរបស់កម្ពុជា"។

យើងខ្ញុំក៏សូមប្រកាសមិនគាំទ្រដាច់ខាតចំពោះគោលជំហររបស់បុគ្គលមួយចំនួនមាននិន្នាការផ្ទុយដែលព្រមឱនក្បាលដាក់បរទេស ដើម្បីជំនួយជាលេសលូកដៃកក្កូរកកាយ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជាដែលជារដ្ឋអធិបតេយ្យ។

ថ្ងៃ ពុធ ១កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៨
**រដ្ឋមន្ត្រី**

**អុឹត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩